NSW HEALTH
July 2005
[DOH-7610]



# ថ្នាំ BCG សំរាប់បង្ការជំងឺរបេង

# BCG (Bacillus Calmette-Guerin) VACCINATION

## ព័ត៌មានសំរាប់អ្នកជំងឺ

## Information for Patients

***របេង* (TB)** គឺជាជំងឺមួយបង្កឡើងដោយបាក់តេរី (ហៅថា *Mycobacterium tuberculosis*)។ របេងសួតគឺជាប្រភេទរបេងកើតមានឡើងទូទៅបំផុត ក៏ប៉ុន្តែជំងឺនេះអាចកើតមានឡើងនៅកន្លែងណាក៏បានដែរ ក្នុងរាងកាយ។ របេងសួតឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត នៅពេលដែលចំហាយដំណក់ទឹកមាត់ ឬកំហាកខ្ចាតចូលទៅលំហអាកាស ដោយសារការក្អក កណ្តាស់ឬក៏ការស្រែកច្រៀង។ មនុស្សដែលនៅជិតនោះអាចស្រូបចូល (ដកដង្ហើមចូល) ចំហាយដំណក់ទឹកមាត់ឬកំហាកទាំងនោះ ហើយអាចឆ្លងរោគរបេងនេះបាន។ មនុស្សភាគច្រើនដែលឆ្លងរោគនេះ គ្មានរោគសញ្ញាអ្វីឡើយ ប៉ុន្តែមនុស្សមួយចំនួនតូច មានរោគរបេងសកម្ម ដែលជាញឹកញយច្រើនកើតឡើងបន្ទាប់ពីការឆ្លងរោគនេះនៅគ្រាដំបូង អស់ពេលជាច្រើនឆ្នាំ។ មនុស្សដែលអាចឆ្លងរោគរបេងនេះ គឺ:

- បណ្តាអ្នកធ្វើដំណើរទៅប្រទេសទាំងឡាយណាដែលមានជំងឺរបេងជាទូទៅ។ ឧទាហរណ៍ តំបន់ជាច្រើននៅអាស៊ីនិងអាហ្វ្រិក
- បណ្តាបុគ្គលិកថែទាំសុខភាពនិងអ្នកថែទាំពពួកក្រុមដែលមានលទ្ធភាពខ្ពស់ក្នុងការមានជំងឺរបេង
- សមាជិកគ្រួសារដែលរស់នៅជិតដិតជាមួយអ្នកដែលមានជំងឺរបេង។

***តើថ្នាំបង្ការ* BCG *ជាអ្វី?*** ថ្នាំ BCG ជាថ្នាំបង្ការមួយមានផ្ទុកអង្គធាតុមេរោគ ដែលផ្តល់កិច្ចការពារខ្លះប្រឆាំងនឹងជំងឺរបេង។ ថ្នាំបង្ការ BCG មិនការពារលោកអ្នកពីការឆ្លងរោគឡើយ បើសិនជាលោកអ្នកមានការប៉ះពាល់ជាមួយនឹងបាក់តេរី (មេរោគ)របេង។ ប៉ុន្តែ ថ្នាំបង្ការនេះ ទំនងនឹងធ្វើឲ្យការឆ្លងរោគកើតមានដោយកន្លែង ហើយមិនធ្ងន់ធ្ងរឡើយ ពោលគឺថ្នាំនេះទំនងជាទប់រាំងមិនឲ្យជំងឺនេះគម្រាមកំហែងដល់អាយុជីវិតឡើយ។ ថ្នាំបង្ការ BCG នេះអាចត្រូវការពេលពី ៦ទៅ ១២អាទិត្យ ដើម្បីបង្កើតនូវសារធាតុស៊ាំ (ការពារ) បាន។ ការចាក់ថ្នាំបង្ការ BCG ប្រហែលជាផ្តល់ភាពស៊ាំប្រឆាំងនឹងជំងឺរបេង បានតែ ៥០% ទៅ ៦០% ប៉ុណ្ណោះ ហើយចំពោះបុគ្គលខ្លះ ថ្នាំបង្ការនេះបាត់បង់ប្រសិទ្ធភាពរបស់ខ្លួន ក្នុងរវាងពេលមួយរយៈកាល ជួនកាលនៅក្នុងរវាងពេលពី៥ទៅ១៥ឆ្នាំ។

*ថ្នាំនេះផ្តល់ផលប្រយោជន៍ច្រើនទៅក្មេង។* ជំពោះក្មេង ថ្នាំបង្ការ BCG អាចការពារពួកគេពីការកើតមានជំងឺរបេងប្រភេទធ្ងន់ធ្ងរ មានដូចជា របេងក្នុងខួរក្បាល (របេងរលាកស្រោមខួរ) ជាដើម។ ផលប្រយោជន៍ចំពោះជនពេញវ័យវិញមានភាពមិនសូវច្បាស់លាស់ឡើយ។

*លោកអ្នកនឹងត្រូវការតេស្តសើស្បែកមួយដើម្បីរកមើលជំងឺរបេង (តេស្ត* ***Mantoux*)** ***[Tuberculin Skin Test (Mantoux test)]*** *មុនពេលទទួលថ្នាំបង្ការ* ដើម្បីឆែកមើលថា លោកអ្នកពុំមានវិជ្ជមានទៅនឹងតេស្តសើស្បែកពីការឆ្លងរោគរបេងគ្រាមុន ឬក្រោយពីបានទទួលថ្នាំបង្ការ BCG ។ ជនដែលមានវិជ្ជមានទៅនឹងការធ្វើតេស្តសើស្បែកនឹងមិនទទួលផលប្រយោជន៍ពីថ្នាំបង្ការនេះឡើយ ហើយអាចមានប្រតិកម្មធ្ងន់ធ្ងរមួយ នៅនឹងកន្លែងចាក់ថ្នាំបង្ការផង។

***គុណវិបត្តិមួយក្នុងចំណោមគុណវិបត្តិទាំងពួងក្រោយពីការទទួលថ្នាំបង្ការ* BCG** គឺថា ថ្នាំនេះជាញឹកញយធ្វើឲ្យការធ្វើតេស្តសើស្បែករកមើលរបេងនាគ្រាអនាគតចេញលទ្ធផលវិជ្ជមាន។ ការណ៍នេះមានន័យថា យើងប្រហែលជាមិន

អាចប្រាប់ឲ្យដឹងថា តើប្រតិកម្មនេះបណ្ដាលមកពីការឆ្លងរោគរបេង ឬក៏ដោយសារតែការទទួលថ្នាំបង្ការ BCG នោះឡើយ។

*មានជនខ្លះដែលមិនគួរទទួលថ្នាំបង្ការ* ***BCG*** *នេះ។* អ្នកដែលមានប្រព័ន្ធការពារខ្លួនទាបខ្សោយ អ្នកដែលបច្ចុប្បន្ននេះមានជំងឺ មានដួចជាអុតតូច ឬក៏នាពេលថ្មីៗនេះ បានទទួលថ្នាំបង្ការមានផ្ទុកអង្គធាតុមេរោគ ឧទាហរណ៍ កញ្ជ្រឹលជាដើម អាចត្រូវគេប្រាប់មិនឲ្យទទួលថ្នាំបង្ការ BCG ឡើយ។  ការពិនិត្យវាយតម្លៃរៀងៗខ្លួននឹងធ្វើឡើង មុននឹងការផ្ដល់ថ្នាំបង្ការ BCG  ហើយលោកអ្នកនឹងត្រូវចុះហត្ថលេខាលើក្រដាសបំពេញពាក្យផ្ដល់ការយល់ព្រមមុននឹងការផ្ដល់ថ្នាំបង្ការនេះ។

*ថ្នាំបង្ការ* ***BCG*** *និងថ្នាំបង្ការដទៃទៀតដែលមានផ្ទុកអង្គធាតុមេរោគ។* អ្នកដែលធ្វើដំណើរទៅបរទេស ដែលត្រូវការថ្នាំបង្ការមានផ្ទុកអង្គធាតុមេរោគ លើសពីមួយ **គួរតែអនុវត្តដូចតទៅនេះ** មុននឹងធ្វើដំណើរ: **ក)** ចាក់ថ្នាំបង្ការមានផ្ទុកអង្គធាតុមេរោគទាំងអស់ នៅក្នុងថ្ងៃតែមួយ ឬក៏ **ខ)** ទុកពេលឲ្យបានយ៉ាងតិច ៤អាទិត្យ គឺចន្លោះពីពេលចាក់ថ្នាំបង្ការ BCG និងថ្នាំបង្ការដទៃទៀត ដែលមានផ្ទុកអង្គធាតុមេរោគ។ ការធ្វើបែបនេះ គឺដើម្បីទុកឲ្យប្រព័ន្ធការពារខ្លួននូវឱកាសដ៏ល្អបំផុត សំរាប់ផ្ដល់ភាពការពារចាំបាច់។ ថ្នាំបង្ការខ្លះក្នុងចំណោមថ្នាំបង្ការមានផ្ទុកអង្គធាតុមេរោគ គឺ: ថ្នាំដំណក់សំរាប់បង្ការគ្រុនពោះវៀន, គ្រុនលឿង, ស្រទ្បាទែន, កញ្ជ្រឹល, ស្អូច (MMR) ។  ថ្នាំបង្ការ BCG និងថ្នាំដំណក់បង្ការគ្រុនស្វិតដៃជើង អាចផ្ដល់ឡើងនៅក្នុងរង្វង់ពេល ៤អាទិត្យ។

*តើការផ្ដល់ថ្នាំបង្ការ* ***BCG*** *នេះបង្កឲ្យមានប្រតិកម្មអ្វីឬទេ?* ដូចគ្នាទៅនឹងថ្នាំបង្ការដទៃទៀតដែរ ប្រតិកម្មអាចកើតមានឡើង ហើយក៏មានសភាពខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដែរ។  ជួនកាលកន្លែងដែលចាក់ថ្នាំបង្ការនេះអាចឈឺ ឬក៏ឡើងហើមក្រហម។ ប្រតិកម្មនេះ តាមធម្មតាអាចគ្រាន់បើវិញ ដោយមិនចាំបាច់មានការព្យាបាលឡើយ។ ការហើមកូនកណ្ដុរនៅនឹងឃ្លៀកឬក ក៏អាចកើតមានឡើងដែរ ដែលជួនកាលត្រូវការការព្យាបាល។ ថ្នាំបង្ការ BCG នេះអាចនាំឲ្យមានការឆ្លងរោគ BCG ពាសពេញខ្លួន ប៉ុន្តែហេតុការណ៍នេះគឺកម្រកើតមានឡើងណាស់។ ការឆ្លងរោគនេះអាចកើតមានឡើងចំពោះជនដែលមានប្រព័ន្ធការពារខ្លួនទាបខ្សោយ ដោយរួមទាំងអ្នកដែលមានវិជ្ជមានមេរោគអេដស៍, អ្នកខ្វះជីវជាតិ ឬក៏អ្នកមានជំងឺធ្ងន់។ នៅក្នុងករណីកម្រ មរណភាពអាចកើតមានឡើងបានដែរ។

*ដោយសារថាថ្នាំបង្ការ* ***BCG*** *មិនការពារទប់ទល់នឹងគ្រោះថ្នាក់នៃការឆ្លងជំងឺរបេងបានទាំងស្រុងនោះ* ការយល់ដឹងអំពីរោគសញ្ញានៃជំងឺរបេងសកម្មគឺជាការសំខាន់។ រោគសញ្ញាទាំងនោះ រួមមាន:ការក្អកមិនឈប់ឈរ (អស់រយៈពេលជាង ៣អាទិត្យ), ការក្អកដោយឈាមជាប់នៅក្នុងកំហាក, គ្រុនក្ដៅ, បែកញើសពេលយប់, ស្រកទម្ងន់ដោយគ្មានមូលហេតុ និងអស់កម្លាំង។  រោគសញ្ញាទាំងនេះអាចកើតមានឡើង ដោយសារមូលហេតុជាច្រើន ប៉ុន្តែ បើសិនជាលោកអ្នកមានរោគសញ្ញាបែបនេះ លោកអ្នកគប្បីពិគ្រោះយោបល់ជាមួយនឹងមន្ទីរពិនិត្យសួតតាមតំបន់ ឬក៏វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក ហើយថតមើលសួតដោយកាំរស្មីអិក្ស។

*តើមានអ្វីកើតឡើងក្រោយពីការផ្ដល់ថ្នាំបង្ការ* ***BCG*** *រួចនោះ?* ក្រោយពីការផ្ដល់ថ្នាំបង្ការ BCG រួចនោះ ស្នាមកន្ទួលតូចមួយពណ៌ក្រហមនឹងលេចឡើង នៅក្នុងរង្វង់ពេលពីមួយទៅបីអាទិត្យ។ ស្នាមតូចនេះមានសភាពទន់ទៅៗ ហើយក្រោយមកក៏បែកធ្លាយ បណ្ដាលឲ្យមានដំបៅតូចមួយ ចំពោះមនុស្សភាគច្រើន។  ដំបៅនោះអាចត្រូវការពេលដល់ទៅ៣ខែ ដើម្បីជាសះស្បើយ ហើយជាធម្មតានឹងបន្សល់ទុកនៅស្លាកស្នាមតូចមួយ។

*ការថែកន្លែងចាក់ថ្នាំបង្ការ នៅក្នុងលក្ខណៈដូចតទៅនេះ:*

- ទុកឲ្យកន្លែងចាក់ថ្នាំនោះជាដោយខ្លួនឯង ហើយសូមរក្សាកន្លែងនោះឲ្យស្ងួតស្អាត។ សូមកុំប្រើថ្នាំក្រមួន ឬក្រែមលាបឲ្យសោះ។
- បើសិនជាចាំបាច់ សូមដាក់បង់ស្បៃរុំរបួសដែលស្អាតគ្មានមេរោគ ដោយរុំកុំឲ្យតឹង ប៉ុន្តែសូមកុំប្រើបង់ស្អិតសំឡី ឬក៏ក្រណាត់ដាក់ដោយផ្ទាល់ទៅលើកន្លែងចាក់ថ្នាំនោះឡើយ។
- សូមចៀសវាងកុំអេះឬក៏ប៉ះទង្គិចកន្លែងចាក់ថ្នាំនោះ។
- លោកអ្នកអាចបន្តសកម្មភាពធម្មតា មានដូចជាការងូតទឹក ហែលទឹក និងកីឡាដទៃទៀត។

## *បើលោកអ្នកមានការបារម្ភអ្វី ឬក៏ជួបប្រទះនឹងប្រតិកម្មអ្វីនោះ សូមទូរស័ព្ទទៅ សេវា(កិច្ចបំរើ)គ្រប់គ្រងនិងបង្ការរបេង (មន្ទីរពិនិត្យសួត) លេខ:*

**References:**

BCG Vaccine and Consumer Medicine Information: Connaught Laboratories: Canada.

Winks M, Levy M, Westly-Wise V. and The NSW Tuberculosis Advisory Committee. (1994). *Controlling Tuberculosis in New South Wales.* New South Wales Health Department. North Sydney.

Barclay L. A review of BCG complications since the introduction of a different BCG vaccine. 2000. CDC: Darwin. (See http://www.nt.gov.au/nths/publich/cdc/vol5/bcg.htm)

Colditz GA, Brewer TF, Berkley CS, Wilson ME, et al Efficacy of BCG vaccine in the prevention of tuberculosis - Meta-analysis of the published literature. *JAMA* 1994; 271 (9): 698-702.

Grange JM. Complications of bacille Calmette-Guerin (BCG) vaccination and immunotherapy and their management. *Comm Dis Pub Hlth 1998;* 1 (2): 84-8.

The Role of BCG Vaccine in the Prevention and Control of Tuberculosis in the United States. *MWR:* April 26, 1996 / Vol. 44 / No. RR-4. US Department of Health and Human Services.

The Australian Immunisation Handbook 7th Edition: National Health & Medical Research Council.